# បញ្ចុបោសថជាតក




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧបាសកទាំងឡាយ ៥០០ ដែលជាអ្នករក្សាឧបោសថ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **អប្បោស្សុក្កោ ទានិ តុវំ កាកោត** *ដូច្នេះជាដើម ។*

*ក្នុងគ្រានោះ ព្រះសាស្តាប្រថាប់លើអលង្កតពុទ្ធាសនៈ នៅកណ្តាលបរិស័ទទាំង ៤ ក្នុងសាលាធម្មសភា ទ្រង់សម្លឹងមើលបរិស័ទដោយព្រះហឫទ័យដ៏ទន់ ដឹងថា ថ្ងៃនេះ ទេសនានឹងកើតឡើងដោយអាស្រ័យពាក្យនិយាយ របស់ឧបាសកទាំងឡាយ ដូច្នេះហើយ ព្រះអង្គត្រាស់ហៅឧបាសក សួរថា ម្នាលឧបាសកទាំងឡាយ ពួកអ្នករក្សាឧបោសថហើយឬ ? កាលពួកឧបាសកទូលថា បពិត្រព្រះដ៏ចម្រើន ពួកយើងខ្ញុំបានរក្សាហើយ ។ ព្រះពុទ្ធត្រាស់ថា ការ*

ដែលអ្នកទាំងឡាយធ្វើនេះល្អហើយ ឧបោសថនេះ ឈ្មោះថាជា វង្ស របស់បោរាណបណ្ឌិតទាំងឡាយ បោរាណបណ្ឌិតទាំងឡាយនាំគ្នានៅដោយការរក្សាឧបោសថ ដើម្បីប្រយោជន៍ដល់ការសង្កត់សង្កិនកិលេសទាំងឡាយមានរាគៈជាដើម យ៉ាងនេះហើយ កាលពួកឧបាសកទូលអង្វរហើយ ទ្រង់ក៏នាំអតីតនិទានមកថា

ក្នុងអតីតកាល មានព្រៃមួយដែលនៅចន្លោះនៃដែនទាំង ៣ មានដែនមគធៈជាដើម ។ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងដែនមគធៈ ចម្រើនវ័យធំហើយ លះបង់កាម ចេញទៅកាន់ព្រៃនោះ ធ្វើអាស្រម បួសជាឥសី សម្រេចការនៅក្នុងព្រៃនោះ ។ នៅក្នុងទីមិនឆ្ងាយពីអាស្រ មរបស់ព្រះពោធិសត្វនោះ មានសត្វព្រាបនិងភរិយានៅក្នុងព្រៃឫស្សីមួយ, មានពស់នៅក្នុងដំបូកមួយ, មានឆ្កែចចកនៅនឹងគុម្ពព្រៃមួយ និងមានខ្លាឃ្មុំនៅនឹងគុម្ពឈើមួយ ។ សត្វទាំង ៤ នោះ តែងចូលមករកឥសីតាមកាល ដើម្បីស្ដាប់ធម៌ ។

ថ្ងៃមួយ សត្វព្រាបនិងភរិយាចេញពីសំបុក ទៅស្វែងរកចំណី ។ មានខ្លែងមួយហើរមកចាប់ព្រាបញីដែលហើរតាមក្រោយព្រាបនោះ ហើយហើរគេចបាត់ទៅ ។ សត្វព្រាបស្ដាប់សំឡេងស្រែករបស់ព្រាបញីហើយ ក៏ហើរត្រឡប់មក សម្ងឹងរក មើលនាងព្រាបត្រូវខ្លែងកំពុងនាំទៅ ។ ចំណែកខ្លែងសម្លាប់ព្រាបញីដែលកំពុងស្រែកឲ្យស្លាប់ហើយបរិភោគ ។ សត្វព្រាបកាលពិបាកចិត្ត ព្រោះព្រាត់ប្រាសចាកនាងព្រាប ទើបគិតថា រាគៈនេះធ្វើឲ្យយើងលំបាកណាស់ ឥឡូវនេះ បើយើងសង្កត់សង្កិនរាគៈនេះ មិនបានទេ នឹងមិនចេញទៅរកចំណី ។ សត្វព្រាបកាត់ផ្ដាច់ផ្លូវគោចរ ទៅកាន់សម្នាក់តាបស សមាទានឧបោសថ ដើម្បីសង្កត់សង្កិនកិលេសមានរាគៈជាដើម ហើយដេកនៅកន្លែងមួយ ។

ចំណែកពស់គិតថា យើងនឹងស្វែងរកអាហារ ទើបចេញពីលំនៅ ត្រាច់ស្វែងរកអាហារក្នុងទីប្រព្រឹត្តទៅរបស់គោ ក្នុងបច្ចន្តគ្រាម ។ គ្រានោះ គោមង្គលពណ៌សសុទ្ធរបស់គាមភោជក បរិភោគអាហារហើយ ដាក់ជង្គង់លើដំបូកមួយ យកស្នែងជល់ដីលេង ពស់ភ័យខ្លាចដោយសំឡេងរបស់គោ ក៏វារចូលទៅក្នុងដំបូកនោះ ។ លំដាប់នោះ គោឧសភៈជាន់ពស់ដោយជើង ។ ពស់ក្រោធខឹងនឹងគោ ទើបចឹក គោស្លាប់ក្នុងទីនោះឯង ។ ពួកអ្នកស្រុក ស្តាប់ថា បានឮថា គោឧសភៈស្លាប់ហើយ ពួកគេទាំងអស់នាំគ្នាមកជាមួយ ហើយយំសោក កន្ទក់កន្ទេញ បូជាគោដោយគ្រឿងក្រអូបនិងកម្រងផ្កាជាដើម ហើយកប់ក្នុងរណ្តៅ រួចចៀសចេញទៅ ។ កាលមនុស្សទាំងឡាយទៅហើយ ពស់ចេញមក គិតថា យើងអាស្រ័យសេចក្តីក្រោធបានសម្លាប់គោនេះ ញ៉ាំងហឫទ័យមហាជនឲ្យចូលដល់សេចក្តីសោក ឥឡូវនេះ បើយើងមិនអាចនឹងគ្របសង្កត់សេចក្តីក្រោធនេះទេ នឹងមិនចេញទៅរកចំណី ដូច្នេះហើយ ទើបត្រឡប់ទៅកាន់អាស្រម សមាទានឧបោសថ ដើម្បីសង្កត់សង្កិនសេចក្តីក្រោធ រួចក៏ដេកនៅកន្ទេងមួយ ។

ចំណែកឆ្កែចចកកាលស្វែងរកអាហារ បានឃើញដំរីស្លាប់មួយ មានចិត្តត្រេកអរដោយគិតថា យើងបានអាហារដ៏ធំ ដូច្នេះទើបទៅខាំប្រមោយ ហាក់បីដូចជាខាំសសរ ។ កាលមិនបានសេចក្តីឆ្ងាញ់ត្រង់ប្រមោយនោះ ទើបខាំភ្លុក ក៏ហាក់ដូចជាខាំថ្ម ។ ខាំពោះ ដូចជាខាំដោកស្រូវ ។ ខាំកន្ទុយ ដូចជាស្វាកដែក ។ ខាំវច្ចមគ្គ (ទ្វារធំ) ហាក់ដូចជាខាំនំផ្អែម ។ ឆ្កែចចកនោះកាលស៊ីដោយអំណាចលោភៈ ទើបចូលទៅក្នុងពោះដំរី នៅក្នុងពោះដំរីនោះ កាលឃ្លានក៏ស៊ីសាច់ កាលស្រេកក៏ផឹកឈាម កាលនឹងដេក ក៏ដេកសង្កត់លើពោះវៀនធំ និងសួត ។ ចចកនោះគិតថា ក្នុងទីនេះ មានបាយទឹក និងទីដេកសម្រេចហើយ យើងនឹងធ្វើអ្វីក្នុងទីដទៃ ដូច្នេះទើបត្រេកអរក្នុងពោះដំរីនោះឯង មិនចេញទៅក្រៅ រស់នៅក្នុងពោះដំរីប៉ុណ្ណោះ ។

ពេលខាងក្រោយមក កាលសាកសពដំរីត្រូវស្ងួតក្រៀមដោយខ្យល់និងកម្តៅ ករីសមគ្គ (ទ្វារលាមក) ក៏បិទ ឆ្កែចចកដែលដេកក្នុងពោះដំរី ទើបមានសរីរៈស្គមលឿង មានសាច់និងឈាមតិច មិនឃើញផ្លូវចេញមក ។ ថ្ងៃមួយ ភ្លៀងមិនមែនរដូវកាល បង្អុរចុះមក ករីសមគ្គកាលត្រូវទទឹកសើម ក៏ទៅជាទន់ សម្តែងប្រហោងឲ្យឃើញប្រាកដ ។ ចចកព្រៃឃើញប្រហោងនោះ គិតថា យើងលំបាកអស់កាលដ៏យូរ យើងនឹងរត់ចេញតាមប្រហោងនេះ ដូច្នេះទើបយកក្បាលបុកទម្លុះករីសមគ្គ ។ កាលចចកនោះស្ទុះចេញមកដោយរហ័សពីទីចង្អៀត រោមសរីរៈទាំងអស់ ក៏ជាប់ទាក់នឹងករីសមគ្គ មានខ្លួនទៅជាមិនមានរោម ហាក់ដូចជាគ្រាប់ត្នោត ។ ចចកគិតថា ព្រោះអាស្រ័យលោភៈ ទើបយើងទទួលសេចក្តីទុក្ខនេះ ឥឡូវនេះ បើយើងមិនអាចគ្រប់សង្កត់លោភៈនេះទេ នឹងមិនស្វែងរកអាហារ ដូច្នេះក៏ទៅកាន់អាស្រមតាបសនោះ សមាទានឧបោសថ ដើម្បីសង្កត់សង្កិនលោភៈ ហើយដេកក្នុងទីដ៏សមគួរមួយ ។

ចំណែកខ្លាឃ្មុំចេញអំពីព្រៃ ត្រូវសេចក្តីឃ្លានគ្របសង្កត់ក៏ទៅកាន់បច្ចន្តគ្រាម ក្នុងដែនមល្លរដ្ឋ ។ ពួកអ្នកស្រុកពោលថា បានឮថា ខ្លាឃ្មុំមក ទើបនាំគ្នាកាន់ធ្នូ និងដំបងជាដើមចេញទៅឡោមព័ទ្ធគុម្ពឈើដែលខ្លាឃ្មុំនោះចូលទៅ ។ ខ្លាឃ្មុំដឹងថា មហាជនមកឡោមព័ទ្ធ ទើបរត់ចេញទៅ ពួកមនុស្សនាំគ្នាវាយខ្លាឃ្មុំដែលកំពុងរត់ទៅនោះ ដោយធ្នូ និងដំបងជាដើម ។ ខ្លាឃ្មុំមានក្បាលបែក មានកប្រឡាក់ឈាម ទៅកាន់លំនៅរបស់ខ្លួន ហើយគិតថា ទុក្ខនេះកើតឡើងដោយអំណាចសេចក្តីល្មោភ ឥឡូវនេះ បើយើងមិនអាចគ្របសង្កត់លោភៈនេះទេ យើងនឹងមិនស្វែងរកអាហារឡើយ ដូច្នេះទើបទៅកាន់អាស្រម សមាទានឧបោសថ ដើម្បីសង្កត់សង្កិនសេចក្តីល្មោភ ដេកក្នុងទីកន្ទែងមួយ ។

ចំណែកតាបស ព្រោះអាស្រ័យជាតិរបស់ខ្លួន បានជាអ្នកលុះក្នុងអំណាចមានះ មិនអាចនឹងញុំាងឈានឲ្យកើតឡើង ។ គ្រានោះ ព្រះបច្ចេកពុទ្ធមួយអង្គ ដឹងភាពជាអ្នកមាន

មានះរបស់តាបសនោះ រួចគិតថា តាបសនេះមិនមែនជាសត្វថោកទាបទេ គឺជាពុទ្ធង្កុរ នឹងបានត្រាស់ដឹងសព្វញ្ញុតញ្ញាណ ក្នុងភទ្ទកប្បនេះ យើងនឹងសម្ដែងអាការកើតឡើង នៃសមាបត្តិឲ្យតាបសនេះធ្វើការសង្កត់សង្កិនមានះ ដូច្នេះហើយ កាលតាបសកំពុងអង្គុយក្នុងបណ្ណសាលានោះ ព្រះបច្ចេកពុទ្ធក៏មកពីព្រៃហិមពាន្តទិសខាងជើង គង់លើផែនថ្មរបស់តាបសនោះ ។ តាបសចេញមកបានឃើញព្រះបច្ចេកពុទ្ធគង់លើអាសនៈរបស់ខ្លួន ព្រោះភាពជាអ្នកមានមានះ លោកក៏អាក់អន់ចិត្ត ចូលទៅជិតព្រះបច្ចេកពុទ្ធ ហើយទះទ្រាមដៃពោលឡើងថា នែមនុស្សកាឡកណ្ណីដ៏ថោកទាប នែសមណៈត្រងោល ព្រោះហេតុអ្វី បានជាមកអង្គុយលើផែនថ្មរបស់យើង ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធពោលនឹងតាបសថា នែសប្បុរស ព្រោះហេតុអ្វី បានជាលោកមានមានះ យើងបានចាក់ធ្លុះបច្ចេកពោធិញាណ ហើយអ្នកនឹងបានជាព្រះសព្វញ្ញុពុទ្ធក្នុងភទ្ទកប្បនេះ អ្នកគឺជាពុទ្ធង្កុរ ដែលបានបំពេញបារមីរួចមកហើយ កន្លងទៅអស់កាលប្រមាណប៉ុណ្ណេះទៀត អ្នកនឹងបានជាព្រះពុទ្ធ អ្នកបានតាំងនៅក្នុងភាពជាព្រះពុទ្ធ នឹងមានឈ្មោះថា សិទ្ធត្ថ រួចហើយ ព្រះបច្ចេកពុទ្ធប្រាប់នាម គោត្ត ត្រកូល និងរឿងរ៉ាវទាំងអស់ចាប់ពីអគ្គសាវកជាដើម ហើយឲ្យឱវាទថា ព្រោះហេតុអ្វី បានអ្នកមានមានះ ជាអ្នកពោលវាចាអាក្រក់ អំពើទាំងនេះ មិនសមគួរដល់អ្នកឡើយ ។ កាលព្រះបច្ចេកពុទ្ធពោលយ៉ាងនេះហើយ តាបសនោះក៏មិនថ្វាយបង្គំព្រះបច្ចេកពុទ្ធ និងមិនសួរថា ខ្ញុំនឹងជាព្រះពុទ្ធ ក្នុងពេលណា ដូច្នេះជាដើមឡើយ ។ ពេលនោះ ព្រះបច្ចេកពុទ្ធពោលនឹងតាបសថា អ្នកចូរដឹងនូវភាពជាធំដោយជាតិរបស់អ្នក និងគុណរបស់យើងចុះ បើអ្នកអាច ចូរប្រព្រឹត្តទៅលើដូចយើងចុះ ដូច្នេះទើបហោះឡើងលើអាកាស ពោយពាយធូលីព្រះបាទរបស់ខ្លួន លើមណ្ឌលជដារបស់តាបស ហើយទៅកាន់ឧត្តរហិមវន្តប្រទេសវិញ ។

កាលព្រះបច្ចេកពុទ្ធទៅហើយ តាបសដល់នូវសេចក្តីសង្វេគ គិតថា សមណៈនេះ មានសរីរៈធ្ងន់យ៉ាងនេះ អាចហោះទៅកាន់អាកាសបាន ហាក់ដូចជាសំឡីដែលគេបោះទៅក្នុងមាត់ខ្យល់ ចំណែកយើងព្រោះមានះនឹងជាតិ ក៏មិនបានថ្វាយបង្គំបាទាព្រះបច្ចេកពុទ្ធដែលមានសភាពបែបនោះ ហើយមិនបានសួរលោកថា ខ្ញុំនឹងបានជាព្រះពុទ្ធក្នុងពេលណា ឈ្មោះថាជាតិនេះ នឹងធ្វើអ្វីបាន ការប្រព្រឹត្តសីលនោះឯង ទើបជាធំលើលោកនេះ មានះនេះកាលចម្រើនឡើងហើយ នឹងនាំយើងចូលទៅកាន់នរក ឥឡូវនេះ បើយើងមិនអាចសង្កត់សង្កិនមានះនេះទេ យើងនឹងមិនទៅរកផលាផល ដូច្នេះទើបចូលទៅកាន់បណ្ណសាលា រួចសមាទានឧបោសថដើម្បីសង្កត់សង្កិនមានះ អង្គុយលើផែនក្តារ ។ កុលបុត្តដែលមានញាណធំក៏បានសង្កត់សង្កិនមានះ ហើយចម្រើនកសិណ បានញុំាងអភិញ្ញា និងសមាបត្តិឲ្យកើតឡើង រួចចេញមកអង្គុយលើផែនថ្ម ដែលនៅខាងចុងទីចង្រ្កម ។

ពេលនោះ សត្វទាំងឡាយមានព្រាបជាដើម ចូលមកថ្វាយបង្គំតាបស រួចអង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះមហាសត្វសួរព្រាបថា ថ្ងៃដទៃៗ ពេលស្មើណេះ អ្នកមិនដែលមកឡើយ អ្នកតែងស្វែងរកអាហារ ក្នុងថ្ងៃនេះ តើអ្នករក្សាឧបោសថឬ ? ព្រាបពោលថា ពិតមែនហើយលោកម្ចាស់ ។ លំដាប់នោះ ព្រះពោធិសត្វពោលថា ព្រោះហេតុអ្វី បានអ្នករក្សាឧបោសថ ដូច្នេះកាលនឹងសួរ ទើបពោលគាថាទី ១ ថា

**អប្បោស្សុក្កោ ទានិ តុវំ កបោត, វិហង្គម ន តវ ភោជនត្ថោ;**
**ខុទំ បិបាសំ អធិវាសយន្តោ, កស្មា ភវំ ឧបោសថិកោ កបោត។**

ម្នាលព្រាប ឥឡូវនេះ អ្នកមានសេចក្តីខ្វល់ខ្វាយតិច ម្នាលបក្សី អ្នកមិនមានសេចក្តីត្រូវការដោយចំណីសោះ ម្នាលព្រាប អ្នកខំអត់ទ្រាំនូវគម្លាន និងសម្រេក ជាសត្វរក្សានូវឧបោសថតើព្រោះហេតុអ្វី ។

ព្រាបស្តាប់ពាក្យនោះហើយ ទើបពោល ២ គាថាថា

អហំ បុរេ គិទ្ធិគតោ កបោតិយា, អស្មិំ បទេសស្មិមុភោ រមាម;
អថគ្គហី សាកុណិកោ កបោតិំ, អកាមកោ តាយ វិនា អហោសិំ។

ក្នុងកាលមុន ខ្ញុំមានចិត្តជាប់នឹងមេព្រាប យើងខ្ញុំទាំងពីរនាក់កំពុងតែរីករាយ (ក្នុងកាម) ក្នុងប្រទេសនោះ ស្រាប់តែសត្វខ្លែង មកចាបយកមេព្រាបទៅ ខ្ញុំក៏អស់សេចក្តីប្រាថ្នា ព្រោះប្រាសចាកមេ ព្រាបនោះ។

នានាភវា វិប្បយោគេន តស្សា, មនោមយំ វេទន វេទយាមិ;
តស្មា អហំ បោសថំ បាលយាមិ, រាគោ មមំ មា បុនរាគមាសិ។

ខ្ញុំរងនូវវេទនាក្នុងចិត្ត ព្រោះព្រាត់ប្រាសចាកមេព្រាបនោះ ហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យរាគៈគ្របសង្កត់ខ្ញុំបានទៀតឡើយ។

កាលព្រាបសរសើរឧបោសថកម្មរបស់ខ្លួនហើយ ព្រះមហាសត្វក៏សួរសត្វនីមួយៗ ក្នុងបណ្តាសត្វទាំងឡាយមានពស់ជាដើម។ សូម្បីសត្វទាំងនោះ ក៏បានព្យាករតាមសេចក្តីពិត។

**(តាបសពោធិសត្វសួរពស់ថា)**

អនុជ្ជុគាមី ឧរគា ទុជិវ្ហ, ទាឋាវុធោ ឃោរវិសោសិ សប្ប;
ខុទ្ទំ បិបាសំ អធិវាសយន្តោ, កស្មា តវំ បោសថិកោ នុ ទីឃ។

ម្នាលពស់ ជាឧរគជាតិ លូនទៅមិនត្រង់ មានអណ្តាតពីរ អ្នកមានចង្កូមជាអាវុធ មានពិសដ៏ពន្លឹក ម្នាលសត្វមានខ្លួនវែង អ្នកអត់ទ្រាំ នូវតម្ងាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី។

(ពស់ពោល ២ គាថាថា)

ឧសភោ អហុ ពលវា គាមិកស្ស, ចលក្កកូ វណ្ណពលូបបន្នោ;
សោ មំ អក្កមិ តំ កុបិតោ អឌំសឹ, ទុក្ខាភិតុណ្ណោ មរណំ ឧបាគា។

*គោឈ្មោលឡើងករបស់អ្នកស្រុក ជាគោមានកម្លាំង មានបូកដ៏យុរយារ បរិបូណ៌ដោយសម្បុរនិងកម្លាំង គោនោះដើរជាន់ខ្ញុំ ខ្ញុំខឹង បានចឹកវាៗ ត្រូវសេចក្ដីទុក្ខគ្របសង្កត់ហើយក៏ស្លាប់ទៅ ។*

តតោ ជនា និក្ខមិត្វាន គាមា, កន្ទិត្វា រោទិត្វា អបក្កមឹសុ;
តស្មា អហំទោសជំ ចាលយាមិ, កោធោ មមំ មា បុនរាគមាសិ។

*លំដាប់នោះ ពួកជនចេញអំពីស្រុក កន្ទក់កន្ទេញ យំទួញ ហើយដើរចៀសចេញទៅ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យសេចក្ដីក្រោធគ្របសង្កត់ខ្ញុំបានទៀត ។*

(តាបសពោធិសត្វសួរចចកថា)

មតាន មំសានិ ពហូ សុសានេ, មនុញ្ញរូបំ តវ ភោជនេ តំ;
ខុទំ បិបាសំ អធិវាសយន្តោ, កស្មា ករិទោសជិកោ សិង្គាល។

*ក្នុងព្រៃស្មសាន មានសាច់របស់សត្វស្លាប់ដ៏ច្រើន សាច់ទាំងនុ៎ះជាភោជន ជាទីគាប់ចិត្តរបស់អ្នក ម្នាលចចក អ្នកខំអត់ទ្រាំនូវគម្វាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។*

(ចចកពោល ៣ គាថាថា)

បវិសិ កុច្ឆឹ មហតោ គជស្ស, កុណបេ រតោ ហត្តិមំសេសុ គិទ្ធោ;
ឧណ្ហោ ច វាតោ តិខិណា ច រស្មិយោ, តេ សោសយុំ តស្ស ករីសមគ្គំ។

ខ្ញុំជាសត្វត្រកួតអរក្នុងសាកសព ញ៉ាំមក្នុងសាច់ដំរីទាំងឡាយ បានចូលទៅក្នុងពោះនៃដំរីធំ ខ្យល់ដ៏ក្ដៅផង រស្មីព្រះអាទិត្យដ៏ក្លៀវក្លាផង របស់ទាំងនោះញ៉ាំងទ្វារអាហាចាស់នៃដំរីនោះឲ្យស្ងួតក្រៀម ។

កិសោ ច បណ្ឌុ ច អហំ ភទន្តេ, ន មេ អហូ និក្ខមនាយ មគ្គោ;
មហា ច មេឃោ សហសា បវស្សិ, សោ តេមយី តស្ស ករីសមគ្គំ។

បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំស្គមលឿង (ក្នុងពោះដំរីនោះ) ខ្ញុំរកផ្លូវចេញមកវិញមិនរួច ស្រាប់តែភ្លៀងធំបង្អុរចុះភ្លាម (ក្នុងពេលនោះ) ភ្លៀងនោះ ធ្វើទ្វារអាហារចាស់នៃដំរីនោះឲ្យទទឹកសើម ។

តតោ អហំ និក្ខមិសំ ភទន្តេ, ចន្ទោ យថា រាហុមុខា បមុត្តោ;
តស្មា អហំបោសថំ បាលយាមិ, លោកោ មមំ មា បុនរាគមាសិ។

បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ទើបខ្ញុំចេញមកដូចជាព្រះចន្ទ ដែលរួចអំពីមាត់នៃរាហូ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យលោភៈគ្របសង្កត់ខ្ញុំទៀតឡើយ ។

(តាបសពោធិសត្វសួរខ្លាឃ្មុំថា)

វម្មីកថូបស្មិំ កិបិល្លិកានិ, និប្បោថយន្តោ តុវំ បុរេ ចរាសិ;
ខុទំ បិបាសំ អធិវាសយន្តោ, កស្មា ភវំបោសថិកោ នុ អជ្ជ។

កាលពីដើម អ្នកធ្លាប់ស៊ីនូវកណ្ដៀរទាំងឡាយលើក្បាលដំបូក ម្នាលខ្លាឃ្មុំ អ្នកខំអត់ទ្រាំនូវគម្លាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

(ខ្លាឃ្មុំពោល ២ គាថាថា)

សកំ និកេតំ អតិហីឡយាជោ, អត្រិច្ឆតា មល្ហគាមំ អគច្ឆិំ;
តតោ ជនា និក្ខមិត្វាន គាមា, កោទណ្ឌកេន បរិពោថយិំសុ មំ។

*ខ្ញុំមើលងាយនូវលំនៅរបស់ខ្លួន បានចូលទៅកាន់ស្រុកនៃមល្លជន ព្រោះតែសេចក្ដីប្រាថ្នាលើសលប់ គ្រានោះ ពួកជនចេញមកពីស្រុក ហើយក៏វាយខ្ញុំដោយធ្នូ ។*

សោ ភិន្នសីសោ រុហិរមក្ខិតង្គោ, បច្ចាគមាសិំ សកំ និកេតំ;
តស្មា អហំ ពោសថំ បាលយាមិ, អត្រិច្ឆតា មា បុនរាគមាសិ។

*ខ្ញុំនោះបែកក្បាលប្រឡាក់ឈាមអស់ទាំងខ្លួន ហើយត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ ព្រោះហេតុនោះ បានជា ខ្ញុំរក្សាឧបោសថ កុំឲ្យសេចក្ដីប្រាថ្នាលើសលប់គ្របសង្កត់បានទៀតឡើយ ។*

*កាលសត្វទាំង ៤ ពោលសរសើរឧបោសថកម្មរបស់ខ្លួនហើយ ងើបក្រោកឡើងថ្វាយបង្គំព្រះមហាសត្វ រួចពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងថ្ងៃដទៃ ពេលស្មើណោះ លោកម្ចាស់តែងទៅរកផលាផល ចុះថ្ងៃនេះ លោកម្ចាស់មិនទៅ ហើយនៅរក្សាឧបោសថ តើព្រោះហេតុអ្វី ដូច្នេះកាលនឹងសួរទើបពោលគាថាថា*

យំ នោ អបុច្ឆិត្ថ តុវំ ភទន្តេ, សព្ពេវ ព្យាករិម្ហ យថាបជានំ;
មយម្បិ បុច្ឆាម តុវំ ភទន្តេ, កស្មា ភវំ ពោសថិកោ នុ ព្រហ្មេ។

*បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានសាកសួរ នូវសេចក្ដីណាចំពោះយើងទាំងឡាយ យើងទាំងអស់គ្នាក៏បានឆ្លើយនូវសេចក្ដីនោះ តាមទំនងដែលខ្លួនបានដឹងរួចហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកយើងសូមសួរលោកម្ចាស់វិញ បពិត្រព្រហ្ម លោកម្ចាស់រក្សាឧបោសថ តើព្រោះហេតុអ្វី ។*

*តាបសពោធិសត្វព្យាករដល់សត្វទាំងនោះថា*

**អនូបលិត្តោ មម អស្សមម្ហិ, បច្ចេកពុទ្ធោ មុហុត្តំ និសីទិ;**
**សោ មំ អវេទិ គតិមាគតិញ្ច, នាមញ្ច គោត្តំ ចរណញ្ច សព្វំ។**

*ព្រះបច្ចេកពុទ្ធ មិនប្រឡាក់ ( ដោយកិលេស) គង់ក្នុងអាស្រមរបស់យើងមួយរំពេច ព្រះអង្គបានញុំាំងយើងឲ្យដឹងនូវទី ដែលត្រូវទៅ និងទីដែលត្រូវមកផង នូវនាមផង នូវគោត្រផង នូវសេចក្ដីប្រព្រឹត្តទាំងអស់ផង ។*

**ឯវម្បហំ ន វន្ទិ តស្ស បាទេ, ន ចាបិ នំ មានគតេន បុច្ឆិំ;**
**តស្មា អហំ បោសថំ បាលយាមិ, មានោ មមំ មា បុនរាគមាសិ។**

*បើទុកជាយ៉ាងនេះ ក៏យើងនៅតែមិនថ្វាយបង្គំព្រះបាទា នៃព្រះបច្ចេកពុទ្ធនោះ ម្យ៉ាងទៀត យើងមិនបានសាកសួរ ព្រោះលុះអំណាចមានះ ហេតុនោះ បានជាយើងរក្សាឧបោសថ កុំឲ្យមានះគ្របសង្កត់យើងបានទៀតឡើយ ។*

*កាលព្រះមហាសត្វពោលហេតុ នៃឧបោសថរបស់ខ្លួនហើយ បានឲ្យឱវាទដល់សត្វទាំងនោះ រួចបញ្ជូនទៅ លោកក៏ចូលទៅកាន់បណ្ណសាលា ។ សត្វទាំងនោះទៅកាន់លំនៅរៀងៗ ខ្លួន ។ ព្រះមហាសត្វមានឈានមិនសាបសូន្យ ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ចំណែកសត្វទាំង ៤ ឋិតនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ហើយក៏ជាអ្នកមានសួគ៌ជាទីទៅខាងមុខដូចគ្នា ។*

*ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ឧបាសក ឈ្មោះថា ឧបោសថនេះជាវង្សរបស់បោរាណបណ្ឌិតទាំងឡាយ ឧបោសថគឺបុគ្គលរក្សាយ៉ាងនេះ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា*

**តទា កបោតោ អនុរុទ្ធោ អហោសិ** *ព្រាបក្នុងកាលនោះ បានមកជា អនុរុទ្ធ*

**អច្ឆោ កស្សបោ** *ខ្លាឃ្មុំ បានមកជាកស្សបៈ*

**សិង្គាលោ មោគ្គល្លានោ** *ចចកបានមកជាមោគ្គល្លាន*

**សប្បោ សារិបុត្តោ** *ពស់បានមកជាសារីបុត្ត*

**តាបសោ បន អហមេវ អហោសិំ** *ចំណែកតាបស គឺ តថាគតនេះឯង ។*

*ចប់ បញ្ចុបោសថជាតក ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត បិដកលេខ ៦០ ទំព័រ ២៧)*

*ថ្ងៃ ពុធ ១៣ កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២៥ ខែ កក្កដា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*